អន្តរបុរី
សម្លេងខ្មែរនៅបរទេស

# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិត ហុក-សាវណ្ណ ក្រោមប្រធានបទ ស្ត្រីម្នាក់បានស្លាប់ទាំងទារកក្នុងផ្ទៃ ព្រោះគ្មានប្រាក់បង់ថ្លៃពេទ្យ

website ៖ www.hoksavann.org

ថ្ងៃទី២៨ មេសា ២០០៩



តាមរបាយការណ៍ពត៌មានពីប្រទេសកម្ពុជា ស្ត្រីខ្មែរម្នាក់ឈ្មោះ វ៉ម-យៀប អាយុ៣៧ឆ្នាំ បានស្លាប់ទាំងទារកនៅក្នុងផ្ទៃ នៅក្នុងមន្ទីរពេទ្យមួយនៅខេត្តប៉ៃលិន ព្រោះគ្មានប្រាក់១០ម៉ឺនរៀលបង់ឲ្យពេទ្យ ។ នៅកម្ពុជាបច្ចុប្បន្ន ពលរដ្ឋខ្មែរជាច្រើនជាអ្នកក្រីក្រ បើគ្មានប្រាក់ឲ្យមន្ទីរពេទ្យឬគ្រូពេទ្យទេ នោះអ្នកជម្ងឺមិនត្រូវបានយកចិត្តទុកដាក់ព្យាបាលឡើយ ។ លោកម៉ាត់-រ៉ន អាយុ៤៨ឆ្នាំ ជាស្វាមីនាងរងគ្រោះ នៅភូមិសំពៅឡិច សង្កាត់ប៉ៃលិន ស្រុកនិងខេត្តប៉ៃលិន បាននាំភរិយាដូចឈ្មោះខាងលើ ដែលឈឺពោះសំរាលកូន ទៅមន្ទីរពេទ្យមួយនៅទីក្រុងប៉ៃលិនក្នុងភាពអាសន្ន ដោយពេទ្យស្រុកមិនអាចធ្វើឲ្យសំ-រាលតាមប្រក្រតីបាន ។ ស្វាមីនិងភរិយាបានទៅដល់មន្ទីរពេទ្យក្រុងប៉ៃលិនម៉ោង១១យប់នៃថ្ងៃ១៥កុម្ភៈ២០០៩ ។ ពេលទៅដល់ អ្នកយាមនៅមន្ទីរពេទ្យមិនបានចាត់ចែងពិនិត្យមើលឲ្យទាន់ពេលវេលាទេ បែរជានិយាយឲ្យបង់ថ្លៃព្យាបាល១០ម៉ឺនសិន ទើបចាត់ចែងពិនិត្យមើលអ្នកជម្ងឺសំរាលកូននោះ ។ ទាំងប្តីទាំងភរិយាដែលកំពុងឈឺពោះស្ទើរតែដាច់ខ្យល់ អង្វរពេទ្យឲ្យជួយសង្គ្រោះឲ្យបានឆាប់ ខ្ញុំគ្មានប្រាក់បង់សេវាពេទ្យទេ ។ តាមអាជ្ញាធរភូមិថា គ្រួសារអ្នករងគ្រោះមានជីវភាពក្រីក្រខ្លាំងណាស់ មានកូនរហូតដល់៧នាក់ ហើយកូននៅក្នុងផ្ទៃនេះ

ជាកូនទី៨ ហើយផ្ទះរបស់គាត់ត្រូវខ្យល់ព្យុះបោកបក់បើងដំបូលខ្ទេចខ្ទីថែមទៀត ។ ទោះបីអ្នកជម្ងឺស្រែកឲ្យជួយសង្គ្រោះយ៉ាងណា ក៏គ្មានបានផលអ្វីឡើយ ក្រុមគ្រូពេទ្យនាំគ្នាចូលបន្ទប់ដេក ទុកអ្នកជម្ងឺឲ្យអង្គុយនៅបរិវេណខាងក្រៅ រង់ចាំរហូតដល់អ្នកជម្ងឺកាន់តែឈឺធ្ងន់ ប្ដីទៅហៅពេទ្យរហូតបីដង បានសុំអង្វរករគ្រូពេទ្យជាបន្តបន្ទាប់ឲ្យជួយសង្គ្រោះ ទោះបីវះកាត់ក៏ដោយ ឲ្យតែគ្រូពេទ្យជួយ។ ស្ត្រីអ្នកជម្ងឺអង្វរថា ពូជួយខ្ញុំផង បើមិនវះខ្ញុំមិនរស់ទេ ។ ពេទ្យគ្មានចម្លើយអ្វីសោះ ដើរចុះដើរឡើង រហូតដល់អ្នកជម្ងឺស្លាប់នៅម៉ោង៥ភ្លឺជាមួយកូនក្នុងផ្ទៃនៃថ្ងៃ១៦កុម្ភៈ២០០៩ ។ អ្នកជម្ងឺដែលត្រូវសង្គ្រោះជាបន្ទាន់ គ្រូពេទ្យបានទុកចោល ៦ម៉ោង គឺពីម៉ោង១១យប់ដល់ម៉ោង៥ភ្លឺ រហូតដល់អ្នកជម្ងឺស្លាប់ ដោយខ្វះករុណាធម៌យកប្រាក់ជាធំ គួរឲ្យសង្វេគណាស់ ។

ក្រោយពីមរណភាព ត្រូវរថយន្តមន្ទីរពេទ្យដឹកយកទៅបូជានៅវត្តរតនសោភណ ហៅវត្តកោងកាង ជាប់ជើងភ្នំយ៉ាតចម្ងាយ១គ.ម.ពីមន្ទីរពេទ្យបង្អែកខេត្តប៉ៃលិន ។ សាកសពនោះមិនត្រូវសមត្ថកិច្ចនគរបាលទៅត្រួតពិនិត្យឡើយ ឬក៏ឲ្យវេជ្ជបណ្ឌិតឯករាជ្យធ្វើកោសល្លវិច័យមុននឹងយកទៅបូជា និងមិនបានអនុញ្ញាតពីប្ដីអ្នកជម្ងឺផង ។ ហេតុអ្វីបានជាគ្រូពេទ្យប្រញាប់ប្រញាល់យកសាកសពទៅបូជា តើមានអាថ៌កំបាំងអ្វីចំពោះការស្លាប់របស់ស្ត្រីឆ្លងទន្លេនេះ ។ លោកសៅ-សឿន ប្រធានគណៈគ្រូពេទ្យប្រចាំខេត្តបាត់ដំបងមានប្រសាសន៍ថា ករណីបែបនេះកើតមានជាច្រើនទូទាំងខេត្ត-ក្រុងនៃប្រទេសកម្ពុជា ប៉ុន្តែពត៌មានទាំងនោះត្រូវបានគេលាក់មិនរាយការណ៍ ។ លោកបន្តថា ករណីម្ដាយនិងកូនស្លាប់ គឺដោយសារគ្រូពេទ្យគិតលុយជាធំ ហើយបោះបង់ចោលក្រមសីលធម៌ដែលខ្លួនត្រូវប្រតិបត្តិ កំហុសពេទ្យពុំមែនកំហុសអ្នកជម្ងឺមករកសេវាពេទ្យទេ គេមិនព្រមព្យាបាល គិតគូរតែរឿងលុយកាក់ ខុសក្រមសីលធម៌ច្បាស់ណាស់ ។

យោលតាមអនុក្រិត្យស្ដីពីក្រមសីលធម៌គ្រូពេទ្យ ដែលទីស្ដីការគណៈរដ្ឋម-ន្ត្រីអនុម័តកាលពីឆ្នាំ២០០៣ ត្រង់មាត្រា២ចែងថា គ្រូពេទ្យត្រូវតែគោរពជីវិតរាងកាយ និងសេចក្ដីថ្លៃថ្នូររបស់មនុស្ស ។ ដូច្នេះគ្រូពេទ្យពុំបានបំពេញកាតព្វកិច្ចរបស់ខ្លួនជាគ្រូពេទ្យ ទើបណ្ដាលឲ្យស្ត្រីជាម្ដាយនិងទារកស្លាប់នៅក្នុងផ្ទៃ ។ តាមរបាយការណ៍ខ្លះថា មានគ្រូពេទ្យ៨នាក់រួមទាំងអនុប្រធានគ្រូពេទ្យផង បានមក

ជួយសង្គ្រោះដែរ តែវាហួសពេលទៅហើយ ដោយសារឈាមចេញច្រើនពេក នាងក៏បានស្លាប់នៅម៉ោង៥ភ្លឺទៅ ។

ការឆ្លងទន្លេនៅប្រទេសជឿនលឿន មិនដែលមានគ្រោះថ្នាក់រហូតដល់ស្លាប់ទេ ។ គេតែងតែសំរាលកូននៅមន្ទីរពេទ្យ បើមិនអាចសំរាលតាមប្រក្រតីទេ គេចាប់វះយកកូនភ្លាមៗ មិនដែលមានគ្រោះថ្នាក់ទេ ម្តាយនិងទារកសង្គ្រោះរស់ទាំងពីរ ។ តាមច្បាប់នៅប្រទេសជឿនលឿន រាល់អ្នកជម្ងឺធ្ងន់ដែលត្រូវសង្គ្រោះជាបន្ទាន់ គ្រូពេទ្យត្រូវតែប្រញាប់ប្រញាល់សង្គ្រោះភ្លាម ទោះបីអ្នកខ្លះមិនមានសំបុត្រធានា (Assurance Maladie, Health Care) ក៏ដោយ ។ សង្គ្រោះរួចហើយ ទើបគិតគូរបញ្ហានោះជាក្រោយ ។ បើមិនបានជួយសង្គ្រោះទេ ទុកឲ្យអ្នកជម្ងឺដែលត្រូវសង្គ្រោះជាបន្ទាន់ស្លាប់ នឹងត្រូវមានទោសតាមច្បាប់ ។ សូម្បីតែឈ្លើយសឹក ដែលគេចាប់បានក្នុងសម័យសង្គ្រាម ក៏ត្រូវយកមកសង្គ្រោះដែរ បើមានជម្ងឺឬត្រូវរបួស ទើបធ្វើតាមច្បាប់ជាក្រោយ ។ ព្រះពុទ្ធសាសនាត្រង់ករុណាធម៌ក្នុងព្រហ្មវិហារធម៌ពោលថា បុគ្គលត្រូវមានការអាណិតអាសូរចំពោះមនុស្សសត្វដែលមានទុក្ខ ហើយគប្បីជួយសង្គ្រោះ ។ ការជួយសង្គ្រោះអ្នកមានទុក្ខជាបុណ្យកុសលខ្ពង់ខ្ពស់ណាស់ ។ ដើម្បីការពារកុំឲ្យមានស្លាប់ដោយការធ្វេសប្រហែសរបស់គ្រូពេទ្យ ដូចករណីអ្នកស្រី រ៉ម-យៀប កើតមានតទៅទៀត គប្បីរាជរដ្ឋាភិបាលនិងក្រសួងសុខាភិបាលចាត់វិធានការយ៉ាងណាឲ្យដឹងច្បាស់ថា អ្នកក្រព្យាបាលមិនយកប្រាក់ ហើយអប់រំក្រមសីលធម៌ដល់គ្រូពេទ្យទាំងអស់ទូទាំងប្រទេសកម្ពុជាផង ។ មួយទៀត គួរអាណិតអាសូរដល់គ្រូពេទ្យ ចំពោះបុគ្គលិកធម្មតាមានប្រាក់ខែទាប គឺបានតែ៣៥ដុល្លារក្នុងមួយខែ គួរពិចារណាដំឡើងឲ្យមានជីវភាពសមរម្យផង ។៚

❄ ❄

❄